ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.....................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១២
## និងទិសដៅការងារឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា

ខេត្តកំពង់ចាម ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣

សូមគោរព :

- ឯកឧត្តម ហ៊ុន ណេង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម
- គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១២ និងទិសដៅការងារឆ្នាំ២០១៣ របស់ធនាគារជាតិនៃកម្ពុជា ដែលរៀបចំឡើងនៅខេត្តកំពង់ចាម ដែលជាខេត្តកសិ-ឧស្សាហកម្ម មានសក្តានុពលផ្នែកសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ។ សន្និបាតយើងថ្ងៃនេះ ត្រូវបានរៀបចំឡើងបន្ទាប់ពីប្រជាជនកម្ពុជានៅទូទាំងប្រទេសបានប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍ទី៣៤ នៃទិវាជ័យជំនះ ៧ មករា លើរបបប្រល័យពូជសាសន៍ ។

ដូចរបាយការណ៍របស់ ឯកឧត្តម ស៊ុំ សន្និសិទ្ធ អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា បានជម្រាបជូនអង្គពិធីហើយថា ជារៀងរាល់ឆ្នាំ យើងតែងតែរៀបចំប្រារព្ធពិធីនេះនៅរាជធានីភ្នំពេញ ដើម្បីផ្សព្វផ្សាយនិងអបអរសាទរចំពោះលទ្ធផលការងាររបស់ខ្លួន ប៉ុន្តែឆ្នាំនេះជាលើកទី១ ដែលយើងបានមករៀបចំនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ចាមម្តង ក្នុងបំណងដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិក ទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្តផ្សេងទៀត បានសិក្សាស្វែងយល់ពីការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តំបន់ប្រវត្តិសាស្រ្ត និងតំបន់រមណីយដ្ឋានទេសចរណ៍នៅខេត្តកំពង់ចាម ។

តាមរយៈរបាយការណ៍របស់ ឯកឧត្តម ហ៊ុន ណេង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ខ្ញុំសូមកោតសរសើរយ៉ាងខ្លាំង និងវាយតម្លៃយ៉ាងខ្ពស់ចំពោះសមិទ្ធផលអភិវឌ្ឍរីកចម្រើនផ្នែកហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត សង្គម និងសេដ្ឋកិច្ចនៅទូទាំងខេត្ត ក្រោមការដឹកនាំរបស់ឯកឧត្តមអភិបាលខេត្ត រហូតដល់បច្ចុប្បន្ននេះ ។ ជាក់ស្តែង អគារសាខាធនាគារជាតិ



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នៃកម្ពុជាខេត្តកំពង់ចាមដែលយើងកំពុងប្រជុំនេះ ក៏ជាស្នាដៃរបស់ ឯកឧត្តម ហ៊ុន ណេង ផងដែរ ដែលបានរួមចំណែកជាមួយខ្ញុំ និងផ្តល់កិច្ចសហការកសាងឡើងនៅឆ្នាំ២០០៦ ។ ពេលនោះ ខ្ញុំបានកត់សម្គាល់ថា វិស័យធនាគារនៅក្នុងខេត្តកំពង់ចាម មិនទាន់មានសកម្មភាពច្រើន ដូចសព្វថ្ងៃទេ មានតែសាខាធនាគារអេស៊ីលីដា និងធនាគារកាណាឌីយ៉ាប៉ុណ្ណោះ ប៉ុន្តែ បច្ចុប្បន្ននេះ មានបណ្តាញសេវានិងសាខាគ្រឹះស្ថានធនាគារយ៉ាងខ្លាំងនៅទូទាំងខេត្ត ។ សមិទ្ធផលរីកចម្រើនទាំងនេះ កើតឡើងដោយសារការដឹកនាំរបស់ ឯកឧត្តម ហ៊ុន ណេង ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងចលនាប្រឡងប្រណាំងទីក្រុងស្អាត របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ទន្ទឹមពេលនេះ តាងនាមថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម ហ៊ុន ណេង ដែលតែងតែគាំទ្រចំពោះដំណើរការអភិវឌ្ឍ ប្រព័ន្ធធនាគារ និងបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមជាគណៈអធិបតីក្នុង អង្គសន្និបាត នាពេលនេះ ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តម លោក-លោកស្រី តំណាងមន្ទីរ-អង្គភាព និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលតែងតែផ្តល់កិច្ចសហប្រតិបត្តិការ ល្អដល់ធនាគារជាតិនៃកម្ពុជា និងបង្កបរិយាកាសឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្នុង ខេត្តកំពង់ចាម ប្រព្រឹត្តទៅដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ។

ស្មារតីកិច្ចសហប្រតិបត្តិការល្អជាប្រពៃណីនេះ គឺជាកត្តាគន្លឹះធ្វើឱ្យការងាររបស់យើង បានទទួលជោគជ័យជាបន្តបន្ទាប់ ។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះមន្ត្រីបុគ្គលិក ធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួល ខុសត្រូវ កសាងសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារ នៅកម្ពុជាឱ្យមានការរីកចម្រើន ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែង របស់រដ្ឋាភិបាល ។

### ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោល បំណងផ្សព្វផ្សាយពីលទ្ធផលការងារសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា នៅឆ្នាំ២០១២ ដូចតទៅ ៖

### I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

នៅឆ្នាំ២០១២ តាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ស្ថានភាព សេដ្ឋកិច្ចពិភពលោកបានបន្តដើបឡើងវិញក្នុងល្បឿនយឺតជាងមុន ដោយសារប្រទេសអភិវឌ្ឍន៍ខ្លះ នៅប្រឈមហានិភ័យនៃការធ្លាក់ចុះនៃសេដ្ឋកិច្ច ប្រព័ន្ធហិរញ្ញវត្ថុនៅមានភាពផុយស្រួយ របៀបវារៈកំណែទម្រង់មិនទាន់អនុវត្តបានពេញលេញ និងជម្រើសគោលនយោបាយស្តារ

សេដ្ឋកិច្ចតាមតំបន់មិនទាន់មានភាពប្រាកដប្រជានៅឡើយ ។ ជាក់ស្តែង សហរដ្ឋអាមេរិក នៅបន្តប្រឈមនឹងអត្រានិកម្មភាពខ្ពស់ ខណៈដែលវិបត្តិបំណុលនៅតំបន់អឺរ៉ុប មិនទាន់បាន ដោះស្រាយចប់នៅឡើយ ។ ដោយឡែក នៅតំបន់អាស៊ី ប្រទេសដែលមានសេដ្ឋកិច្ចកំពុង ងើបឡើង បន្តមានកំណើនវិជ្ជមាន ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ដោយសារផលប៉ះពាល់ពី ខាងក្រៅដែលបានធ្វើឱ្យការនាំចេញ និងការវិនិយោគថយចុះ។

ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០១២ នឹងមានកំណើន ៣,៣% ធៀបនឹង ៣,៨% នៅឆ្នាំ២០១១ ។ ស្ថានភាពសេដ្ឋកិច្ចនៅសហគមន៍អឺរ៉ុបអាចមាននិន្នាការធ្លាក់ចុះ ក្នុងកម្រិតមួយទាប ខណៈដែលប្រទេសជឿនលឿនមួយចំនួននៅក្រៅតំបន់អឺរ៉ុប រួមទាំង ប្រទេសជប៉ុនផង កំពុងប្រឈមនឹងកំណើនទាបនៅឡើយ ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិក មានកំណើន ២,២% ។ ចំណែកសេដ្ឋកិច្ចតំបន់អាស៊ីមានអត្រាកំណើន ៥,៥% ក្នុងនោះ ប្រទេសចិន ៧,៨% ជប៉ុន ២,២% ឥណ្ឌា ៤,៩% និងអាស៊ាន៥ មានកំណើន ៥,៤% ។ ស្ថានភាពល្អប្រសើរនេះ ដោយសារតំបន់អាស៊ីមានមូលដ្ឋានសេដ្ឋកិច្ចរឹងមាំ និងបានអនុវត្ត គោលនយោបាយសារពើពន្ធនិងរូបិយវត្ថុទន់ភ្លន់ ដែលជារនាំងទប់ស្កាត់ការឆ្លងរាលដាល នៃវិបត្តិទីផ្សារហិរញ្ញវត្ថុ ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ បានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។ តាមការព្យាករណ៍របស់រាជរដ្ឋាភិបាលថា នៅឆ្នាំ២០១២ សេដ្ឋកិច្ចនឹងមានកំណើនប្រមាណ ៧% ធៀបនឹង ៧,១% នៅឆ្នាំ២០១១ ។ កំណើននេះ គាំទ្រដោយវិស័យកសិកម្ម ៣,២% ឧស្សាហកម្ម ១៣,៣% សេវាកម្ម ៥% និងវិនិយោគផ្ទាល់បរទេស គួបផ្សំនឹងការអនុវត្តគោល នយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើពិពិធកម្មវិស័យផលិតកម្ម ជាពិសេស វិស័យកសិកម្ម និងពិពិធកម្មទីផ្សារនាំចេញផង ពិតជាបានរួមចំណែកគាំទ្រដល់ស្ថិរភាពម៉ាក្រូ សេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ស្របតាមការព្យាករណ៍របស់រាជរដ្ឋាភិបាល ។

### II/- លទ្ធផលការងារសំខាន់ៗដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន

អនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួនតាមច្បាប់ ក្នុងការរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូ សេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ បានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ដោយរក្សាបាននូវស្ថិរភាពថ្លៃ ស្ថិរភាពនៃតម្លៃប្រាក់រៀល និងគ្រប់គ្រងអត្រាអតិផរណាក្នុង កម្រិតទាប ប្រែប្រួលក្នុងកម្រិតមួយអាចគ្រប់គ្រងបាន ប្រកបដោយប្រសិទ្ធភាព ។ ជារួម នៅឆ្នាំ២០១២ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ននិងទន់ភ្លន់ ឃើញថា ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សា ស្ថិរភាពល្អប្រសើរ និងបានគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ប្រកបដោយប្រសិទ្ធភាព ។

សមិទ្ធផលទាំងនេះ អាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ ដូចខាងក្រោម ៖

នៅក្នុងឆ្នាំ២០១២ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារបានឡើងថ្លៃប្រមាណ ១,៧% ធៀបនឹងឆ្នាំ២០១១ ។ អត្រាអតិផរណាមាននិន្នាការថយចុះ គួរឱ្យកត់សម្គាល់ ពី ៥,៥% នៅឆ្នាំ២០១១ មក ៣% នៅឆ្នាំ២០១២ ។ រូបិយវត្ថុទូទៅ (M2) មានកំណើនឆ្នាំលើឆ្នាំ ១៨,៥% បណ្តាលមកពីកំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារចំនួន ១៥,៨% និងកំណើនទ្រព្យសកម្មក្នុងស្រុកសុទ្ធចំនួន ៥០% ។ ទុនបម្រុងអន្តរជាតិសរុបបានកើនឡើងរហូតដល់ ៣.៧០០ លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបាន ចំនួនប្រមាណ ៤,៥ខែ ។ ការគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ននិងតាមគោលការណ៍ណែនាំ ស្របតាមភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ចជាតិ ។ ស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀល បានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម ៖

**១/- វិស័យធនាគារ** : មានសុខភាពល្អ សុវត្ថិភាព និងមានការអភិវឌ្ឍនិងរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ហើយបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ផ្នែកវិសាលភាពប្រព័ន្ធធនាគារនាពេលបច្ចុប្បន្ន មានធនាគារពាណិជ្ជចំនួន៣២ ធនាគារឯកទេសចំនួន៧ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣៥ ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ ត្រូវបានអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីចំនួន៣២ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន១ និងការិយាល័យព័ត៌មានឥណទានចំនួន១ ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុភាគច្រើនមានបណ្តាញសេវានិងសាខានៅទូទាំងប្រទេស ។

ចំពោះទំហំប្រតិបត្តិការវិញ យើងសង្កេតឃើញថា ដោយសារស្ថានភាពល្អប្រសើរនិងអំណោយផលនៃសេដ្ឋកិច្ច ប្រាក់បញ្ញើនិងឥណទានក្នុងប្រព័ន្ធធនាគារបានបន្តកើនឡើងជាលំដាប់ ។ ការវិវត្តរីកចម្រើននេះ គួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នផងនោះ បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះជាបន្តបន្ទាប់ ។

ប្រការដែលគួរឱ្យកត់សម្គាល់នៅឆ្នាំ២០១២ គ្រឹះស្ថានធនាគារបានបន្តពង្រីកបណ្តាញសេវានិងសាខារបស់ខ្លួននៅក្នុងប្រទេស និងបានបើកការិយាល័យតំណាងរបស់ខ្លួននៅបរទេស គឺ ប្រទេសឡាវនិងភូមាផងដែរ ។ ចំពោះផលិតផលហិរញ្ញវត្ថុនៅក្នុងវិស័យធនាគារបានបន្តរីកចម្រើនជាលំដាប់ ដូចជា ការកើនឡើងនៃចំនួនម៉ាស៊ីន ATM រួមទាំង សេវាបណ្ណឥណពន្ធ, បណ្ណឥណទាន, សេវាសន្សំជាមាស, សេវាធនាគារ E-banking, និងប្រតិបត្តិករធនាគារចល័តជាដើម ក៏មានការរីកចម្រើនឥតឈប់ឈរនៅទូទាំងប្រទេសផងដែរ ។

**២/- វិស័យមីក្រូហិរញ្ញវត្ថុ** : មានការរីកចម្រើនយ៉ាងខ្លាំង ត្រូវបានគេចាត់ទុកថាជាវិស័យគន្លឹះក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ជាក់ស្តែង ចំនួនអតិថិជនដែលបានទទួលឥណទានពីវិស័យនេះ បានកើនជាង ១.៣០០.០០០ នាក់ និងមានឥណទានសរុបកើនដល់ចំនួន ៣.៤៧៣ ពាន់លានរៀល គឺកើនឡើងប្រមាណ ៣៤% ធៀបនឹងឆ្នាំ២០១១ ។ ប្រាក់បញ្ញើវិញមានចំនួន ១.០៥៣ ពាន់លានរៀល កើនចំនួន ១២៩% ពីអ្នកផ្ញើប្រាក់ចំនួន ៥០៤.៨៤០ នាក់ ។ ការរីកចម្រើននេះ បានរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។

**៣/- ការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** : ខណៈដែលវិស័យហិរញ្ញវត្ថុមានភាពប្រទាក់ក្រឡាគ្នា និងប្រឈមនឹងហានិភ័យនៃវិបត្តិទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិកម្ម បានពង្រឹងការត្រួតពិនិត្យសុខភាពគ្រឹះស្ថានធនាគារជាប់ជាប្រចាំ តាមរយៈការចុះទៅត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារ ក្នុងបំណងដើម្បីជួយពង្រឹងអភិបាលកិច្ចល្អនិងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ។ នៅឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន១៩ ធនាគារឯកទេសចំនួន៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន១៣ និងប្រតិបត្តិករឥណទានជនបទចំនួន៥ ។

ជារួម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសុខភាពល្អ មានស្ថានភាពហិរញ្ញវត្ថុរឹងមាំ និងគោរពតាមវិធានការប្រុងប្រយ័ត្ន ។ ប៉ុន្តែ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណាដែលមានចំណុចខ្វះខាត យើងបានផ្តល់អនុសាសន៍ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែងផងដែរ ។

**៤/- ការដាក់ឱ្យដំណើរការការិយាល័យឥណទាន** : បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុនក្រេឌីតប្យ៉ូរ៉ូកម្ពុជាបានដាក់ឱ្យដំណើរការនូវប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាផ្លូវការ នៅខែមីនា ឆ្នាំ២០១២ ។ បច្ចុប្បន្ន មានគ្រឹះស្ថានធនាគារចំនួន ៣៧ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣២ បានចូលជាសមាជិក ។ ការចូលជាសមាជិកដើម្បីប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះ នឹងជួយ *(១)*- បង្កើនបរិយាកាសអាជីវកម្មឱ្យកាន់តែប្រសើរឡើង និងកាត់បន្ថយពេលវេលានៃការផ្តល់ឥណទាន និង*(២)*- កាត់បន្ថយហានិភ័យនៃការផ្តល់ឥណទានជាន់គ្នា ហើយជួយឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្គាល់អតិថិជនរបស់ខ្លួនកាន់តែច្បាស់ (KYC) ។

**៥/- ការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិ** : ធនាគារជាតិនៃកម្ពុជា បានរៀបចំប្រព័ន្ធទូទាត់សងប្រាក់ ដែលមានលក្ខណៈមជ្ឈការ ដើម្បីសម្រួលដល់ការទូទាត់ពាណិជ្ជកម្មឱ្យកាន់តែសម្បូរបែប និងមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់ឧបករណ៍ទូទាត់ផ្សេងៗ ដូចជា មូលប្បទានបត្រ

និងការផ្ទេរអេឡិចត្រូនិកជាដើម ។ ដើម្បីសម្រួលប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជាបានបំពាក់ Client Module ដល់សមាជិកសភាផាត់ទាត់ចំនួន ៣៨គ្រឹះស្ថាន និងសាខាធនាគារជាតិនៃកម្ពុជាដែលមានសភាផាត់ទាត់ ។

ក្រៅពីនេះ យើងបានរៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងក្រុមហ៊ុន ឬគ្រឹះស្ថានមិនមែនធនាគារ រួមទាំងក្រុមហ៊ុនទូរសព្ទចល័តដែលធ្វើជាអ្នកដំណើរការតតិយភាគីក្នុងការផ្តល់សេវាផ្ទេរប្រាក់ ឬសេវាទូទាត់ផ្សេងៗទៀត ដើម្បីធ្វើប្រតិបត្តិការរបស់ខ្លួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជាផងដែរ ។

**៦/- ការពង្រឹងអភិបាលកិច្ចល្អ និងសុវត្ថិភាពធនាគារកណ្តាល :** ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចឱ្យស្របតាមគោលការណ៍ត្រួតពិនិត្យផ្ទៃក្នុងតាមរយៈការបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា ដាក់ចេញនូវបទប្បញ្ញត្តិនានា បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ។ ជាក់ស្តែង នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចេញផ្សាយរបាយការណ៍សវនកម្មសម្រេចនៃនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ នាយកដ្ឋានប្រតិបត្តិការ ខុទ្ទកាល័យ ព្រមទាំងសាខាខេត្តស្វាយរៀង កំពត តាកែវ ក្រចេះ កំពង់ឆ្នាំង ពោធិ៍សាត់ ព្រៃវែង ស្ទឹងត្រែង សៀមរាប និងសាខាខេត្តកំពង់ចាម ។ ក្រៅពីនេះ យើងក៏បានផ្តល់អនុសាសន៍នានាសម្រាប់កែលម្អចំណុចខ្វះខាតមួយចំនួន សំដៅកាត់បន្ថយហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

ចំពោះការងារអធិការកិច្ចវិញ យើងបានចុះត្រួតពិនិត្យនៅសាខាធនាគារជាតិនៃកម្ពុជាបានចំនួន១៥ ដោយផ្តោតជាសំខាន់ទៅលើការធានាសុវត្ថិភាពឃ្លាំងប្រាក់ ការគ្រប់គ្រងសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវុឌ្ឍិ វិន័យការងាររបស់មន្ត្រីបុគ្គលិក និងប្រសិទ្ធភាពការងារនៅតាមសាខាឱ្យកាន់តែប្រសើរ ។

**៧/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត :** ដូចក្នុងរបាយការណ៍របស់ ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានបញ្ជាក់ហើយថា ដើម្បីសម្របសម្រួលសាច់ប្រាក់ និងបន្តអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ជំហានទី២ យើងបានពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួន ដោយបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា បណ្តុះបណ្តាលផ្នែកការងារ ប្រតិបត្តិការនិងជំនាញ IT និងរៀបចំការងារចាត់តាំងមន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ស្របតាមការងារនិងស្ថានភាពសេដ្ឋកិច្ចជាក់ស្តែងនៅក្នុងរាជធានី-ខេត្ត ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិជាលក្ខណៈទ្វេភាគីនិងពហុភាគីវិញ ធនាគារជាតិនៃកម្ពុជា មានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ ហើយសម្រេចបានសមិទ្ធផលដូចតទៅ ៖

**១/- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)** : នៅឆ្នាំ២០១២ ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជាចំនួន ៥លើក ។ ទី១/- ដើម្បីពិភាក្សាពី វឌ្ឍនភាពការងារស្ថិតិនិងជញ្ជីងទូទាត់ ការរៀបចំផែនការសកម្មភាព និងអនុសាសន៍ថ្មី ស្របតាម ស្តង់ដារស្ថិតិរូបិយវត្ថុអន្តរជាតិ ។ ទី២/- ដើម្បីពិនិត្យការវិវត្តរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ច និងពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នៅឆ្នាំ២០១២ និងឆ្នាំ២០១៣ ។ ជាលទ្ធផល អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានវាយតម្លៃល្អពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា ជាពិសេស ចំពោះ សមិទ្ធផលនានាដែលធនាគារជាតិនៃកម្ពុជា ខិតខំរក្សាស្ថិរភាពថ្លៃ និងស្ថិរភាព ប្រព័ន្ធហិរញ្ញវត្ថុ ក្នុងរយៈពេលខ្លីនិងមធ្យមបានប្រសើរ និងបានជួយគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។

ទី៣/- ជាបេសកកម្មប្រចាំគ្រានៃកិច្ចពិភាក្សាមាត្រាទី៤ ដើម្បីបន្តការតាមដានការវិវត្ត និងវិភាគអំពីស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា ទី៤/- ជាទស្សនកិច្ចឯកឧត្តម Naoyuki Shinohara អនុប្រធានមូលនិធិរូបិយវត្ថុអន្តរជាតិ បានដឹកនាំគណៈប្រតិភូមកចូលរួម កិច្ចប្រជុំកំពូលអាស៊ាន និងទី៥/- ក្រុមបេសកកម្មរបស់នាយកដ្ឋានទីផ្សាររូបិយវត្ថុនិងដើមទុន IMF ដើម្បីស្វែងយល់ពីបញ្ហានិងវឌ្ឍនភាពទីផ្សារ និងប្រតិបត្តិការទីផ្សារប្តូរប្រាក់នៅកម្ពុជា ។

**២/- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** : ធនាគារអភិវឌ្ឍន៍អាស៊ីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។ ស្ថិតក្រោមជំនួយបច្ចេកទេសរបស់ ADB រាជរដ្ឋាភិបាលបានអនុម័ត និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ប្រកបដោយជោគជ័យ កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ ។ ធនាគារជាតិនៃកម្ពុជានឹងសហការជាមួយ ADB និងក្រសួងពាក់ព័ន្ធ ដើម្បីបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យមានការរីកចម្រើនបន្ថែមទៀត។

**៣/- ការងារអាស៊ាន និងអាស៊ាន+៣**: ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាល និងថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី២០ និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀតនៅរាជធានីភ្នំពេញ នៅចុងខែមីនា ឆ្នាំ២០១២ ។

នៅដើមខែឧសភា ឆ្នាំ២០១២ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាក៏បានចូលរួមប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ លើកទី១៥ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។ នេះជាកិច្ចប្រជុំលើកដំបូងក្នុងប្រវត្តិសាស្ត្រអាស៊ាន ដែលរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលអាស៊ាន+៣ បានជួបពិភាក្សាគ្នា ដើម្បីពិភាក្សានិងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរូបិយវត្ថុនិងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ក្នុងតំបន់ ។

**៤/- មជ្ឈមណ្ឌល SEACEN** : កិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល SEACEN មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវ ។ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលធនាគារកណ្តាលស៊ាសិនលើកទី៣១ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ និងលើកទី៣២ នៅទីក្រុងអ៊ូឡានបាតា ប្រទេសម៉ុងហ្គោលី និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ (EXCO) លើកទី១០ នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា និងលើកទី១១ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េ ។

ក្នុងក្របខ័ណ្ឌស៊ាសិន ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយធនាគារកណ្តាលអង់គ្លេស ធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសិក្ខាសាលាលើកទី៥ ស្តីពី **ការគ្រប់គ្រងនយោបាយរូបិយវត្ថុនិងម៉ាក្រូសេដ្ឋកិច្ច** នៅចុងខែមីនា ឆ្នាំ២០១២ និងរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាលស៊ាសិនលើកទី៣ នៅចុងខែសីហា ឆ្នាំ២០១២ នៅខេត្តសៀមរាប ប្រកបដោយជោគជ័យ ។ ក្រៅពីនេះ យើងបានបញ្ជូនមន្ត្រីជំនាញ ចូលរួមកិច្ចប្រជុំសិក្ខាសាលានិងវគ្គសិក្សានានារបស់ស៊ាសិនជាប់ជាប្រចាំ ។

**៥/- ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone)** : ប្រតិភូធនាគារជាតិនៃកម្ពុជាតែងតែបានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) ជារៀងរាល់ឆ្នាំ ដើម្បីផ្លាស់ប្តូរយោបល់និង បទពិសោធន៍ ក្នុងការគ្រប់គ្រងប្រតិបត្តិការធនាគារកណ្តាល ការដឹកនាំគោលនយោបាយរូបិយវត្ថុ និងការពង្រឹងកិច្ចសហប្រតិបត្តិការរូបិយវត្ថុ ។ នៅចុងខែឧសភា ឆ្នាំ២០១២ គណៈប្រតិភូធនាគារជាតិនៃកម្ពុជាបានអញ្ជើញទៅចូលរួមសន្និសីទប្រចាំឆ្នាំ ថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង លើកទី១៩ នៅប្រទេសម៉ូរីស ។

**៦/- សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA)** : ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតលើកទី១៨ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ APRACA លើកទី៦១ និងសន្និសីទថ្នាក់តំបន់ស្តីពី ការពង្រឹងសមត្ថភាពកសិករខ្នាតតូច តាមរយៈ

ភាពច្នៃប្រឌិតនៃហិរញ្ញវត្ថុជនបទ នៅខេត្តសៀមរាប ប្រកបដោយជោគជ័យ ។ ធនាគារជាតិនៃកម្ពុជា ត្រូវបានជ្រើសតាំងជាប្រធានសមាគមនេះសម្រាប់អាណត្តិរយៈពេល ២ឆ្នាំ ចាប់ពីខែមិថុនា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៤ ។

**៧/- កិច្ចសហប្រតិបត្តិការទ្វេភាគី** មានការរីកចម្រើនជាលំដាប់ ។ យើងបានពង្រឹងនិង ពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ឆេក លុចហ្សំបួរ អាល្លឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ាន និង អាស៊ាន+៣ លើផ្នែកបណ្តុះបណ្តាលធនធានមនុស្សនិងផ្លាស់ប្តូរបច្ចេកទេស ។ នៅខែមីនា ឆ្នាំ២០១២ នេះ យើងបានបើកកិច្ចប្រជុំទ្វេភាគី និងចុះហត្ថលេខាលើអនុស្សារណៈយល់គ្នា ចំនួនពីរជាមួយធនាគាររដ្ឋវៀតណាម អំពី **ការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្ម** និង **ការបណ្តុះបណ្តាល** នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ នៅទីក្រុងភ្នំពេញ ។ កាលពីចុងខែធ្នូ ឆ្នាំ២០១២ គណៈប្រតិភូធនាគារជាតិនៃកម្ពុជា បានអញ្ជើញទៅចូលរួមកិច្ចប្រជុំ ទ្វេភាគីជាមួយធនាគារកណ្តាលឡាវ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី នៅខេត្ត ចម្ប៉ាសាក់ ប្រទេសឡាវ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងនេះ កើតចេញពីការប្រើប្រាស់កម្លាំងសរុបរបស់មន្ត្រីបុគ្គលិក យើង ដែលខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការចូលរួម សហការពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាត មេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹង រាយការណ៍លម្អិតជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍធនាគារជាតិនៃកម្ពុជា ឱ្យរីកចម្រើននិងសម្រេចបានសមិទ្ធផលជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះ តទៅទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលមួយថ្ងៃកន្លះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែល អនុវត្តកន្លងមក និងលើកទិសដៅការងារឆ្នាំ២០១៣ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឱ្យ បានជោគជ័យ និងមានប្រសិទ្ធភាព ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ ឯកឧត្តម ហ៊ុន ណេង និងគណៈអធិបតី សូមមានសុខភាពល្អ និងទទួលបានជ័យជំនះគ្រប់ភារកិច្ច ។ ខ្ញុំសូមជូនពរផងដែរ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឱ្យអង្គសន្និបាតរបស់យើងមានដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ**!